ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

## ឆ្នាំដំបូង

ខែ ១ ដល់ ១២

កុងស៊ីយ៍សេនាបតីបានអនុញ្ញាតហើយ

ក្រុងភ្នំពេញ

រោងពុម្ពរាជការ គូវីរណេមិត្ត

គ្រិ. ឆ្នាំ ១៩២៦

ព. ស. ២៤៧២

# កាលាមសូត្រ

គឺព្រះមហាវិមលធម្ម

ចាងហ្វាងសាលាបាលីជាន់ខ្ពស់

ប្រែចេញពីគម្ពីរអង្គុត្តរនិកាយ តិកនិបាត

ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូរ

អាចារ្យព្រះរាជបណ្ណាល័យ

បានទទួលផ្ទៀងផ្ទាត់រួចហើយ

ទស្សនាវដ្ដីកម្ពុជសុរិយា

ឆ្នាំដំបូង

ខែ១-១២

ព.ស.២៤៧២ គ.ស.១៩២៦



ព្រះសពព្រះមហាវិមលធម្ម (ព្រហ្មបណ្ឌិត រ័ត៌ន-ថោង)
អតីតចាងហ្វាង សាលាបាលីជាន់ខ្ពស់ ព្រះជន្មាយុ ៦៤ឆ្នាំ

២៤០៦-២៤៧០

# កាលាមសូត្រ

## សេចក្តីផ្តើម

ព្រះមហាវិមលធម្ម ថោង ចាងហ្វាងសាលាបាលីជាន់ខ្ពស់ សូមថ្វាយព្រះរាជកុសលចំពោះព្រះករុណា ជាម្ចាស់ជីវិត ព្រះចៅក្រុងកម្ពុជា ដោយអាត្មាភាពបានរៀបរៀងសៀវភៅ កាលាមសូត្រ ប្រែចេញពីបាលីគម្ពីរអង្គុត្តរនិកាយ តិកនិបាត ហើយបានទាំងទទួលពិនិត្យសៀវភៅពុទ្ធពង្សាវតារ របស់លោក មោនសៀហ៊ីណូត៍ ចាងហ្វាងសាលាបារាំងសែសនៅទិសបូព៌ា ដែលលោកបានរៀបរៀង ប្រែចេញពីគម្ពីរភាសាបាលីនិងភាសាសំស្ក្រឹតនិងសេចក្តីក្នុងចម្លាក់ថ្ម ដែលព្រះបាទធម្មាសោកទ្រង់ឲ្យឆ្លាក់ទុកនៅក្នុងស្រុកមជ្ឈិមប្រទេស នោះមកជាភាសាបារាំងសែស ហើយ ម៉ាដឺម៉ូអាហ្សែលការបឺឡែស បានឲ្យអ្នកអង្គម្ចាស់វឌ្ឍនាវង្សប្រែចេញមកជាភាសាខ្មែររួចហើយ ទើបប្រគល់មកលោកគ្រូ វិមលបញ្ញា (អ៊ុម-ស៊ូរ) និងលោកព្រះគ្រូសំវិជ្ជា (តាត) ផ្ទៀងផ្ទាត់តាមភាសាបាលីនិងភាសាសំស្ក្រឹតខ្លះ ហើយនឹងភាសាខ្មែរ និងសៀវភៅអភិធម្មត្ថសង្គហៈ ជា

របស់លោកព្រះគ្រូវិមលបញ្ញា (អ៊ុម-ស៊ូរ) បានរៀបរៀងជាមួយនឹងព្រះគ្រូសំវិជ្ជា (តាត) ប្រែចេញពីបាលី អភិធម្មត្ថសង្គហៈ ព្រមទាំងដីកា ហើយនឹងលោកព្រះគ្រូសំសត្ថា (ឈាត) ក៏បានជួយទំនុកបម្រុងក្នុងការរៀបរៀងសៀវភៅនេះដែរ និងគតិលោករបស់ឧកញ៉ាសុត្តន្តប្រីជា ឥន្ទ បានតែងទុកមករួមគ្នាទាំងអស់ត្រូវជា៤សៀវភៅ ក៏ឃើញថាត្រឹមត្រូវតាមគតិធម៌ គតិលោក ឥតមានទាស់អ្វីឡើយជារបស់មានប្រយោជន៍ដល់ជនានុជនក្នុងលោកនេះ និងលោកខាងមុខផង។

ម្យ៉ាងទៀតដែលនឹងកើតឡើង ជាសៀវភៅទាំងនេះ នោះដោយសេចក្ដីឧស្សាហ៍និងការទំនុកបម្រុងរបស់ម៉ាដឺម៉ូអាហ្សែលការ-បឺឡែស ជាអ្នករក្សាហោព្រះរាជបណ្ណាល័យ បានចាត់ចែងឲ្យសៀវភៅទាំងនេះ បានឡើងកាន់ពុម្ព ដើម្បីឲ្យបានសម្រេចតាមសេចក្ដីប្រាថ្នារបស់ជនានុជនទាំងឡាយ។

***

# និទានវចនៈ

# ពាក្យលំនាំជាហេតុជាឱតម្គល់ខាងដើម

***

*ព្រះពុទ្ធសករាជ ២៥៦៨*

*មហាសករាជ ១៩៤៧ ចុល្លសករាជ ១២៨៧*

*គ្រឹស្តសករាជ ១៩២៦ បច្ចុប្បន្នឆ្នាំឆ្លូវសប្តស័ក។*

*ព្រះមហាវិមលធម្ម ឧត្តមមេធាវីមហាបរិយត្តិនាយក*

*ចាងហ្វាងសាលាបាលីជាន់ខ្ពស់។*

*យើងសូមប្រកាសសេចក្តីពិតរបស់យើង ដែលយើងបានពិនិត្យពិចារណាមើលធម៌វិន័យ ដែលជាព្រះពុទ្ធវចនៈ ដែលមានក្នុងគម្ពីរព្រះត្រៃបិដកដោយច្រើន ហើយបានយល់ឃើញន័យផ្សេងៗចំពោះខ្លួនដល់សាធុសប្បុរសទាំងឡាយ ដែលជាអ្នកប្រតិបត្តិតាមពុទ្ធឱវាទប្រាកដ ដើម្បីសម្អាតចិត្តឲ្យស្អាតចាកមន្ទិល គឺរាគាទិក្កិលេសទាំងពួង ហើយប្រាថ្នានឹងឈោងចាប់យក លោកុត្តរធម៌ ជាធម៌សម្រាប់ធ្វើឲ្យផុតចាកទុក្ខក្នុងខាងមុខ។*

ហៃសាធុសប្បុរសទាំងឡាយ សម័យនេះ ជាសម័យដ៏ឧត្តម ប្រសើរពេកណាស់ ដោយព្រះករុណាជាម្ចាស់ជីវិត នូវរាជការប្រូ-តិកតួរាត់បារាំងសែសជាធំ ក៏លោកជួយឧបត្ថម្ភទំនុកបម្រុងពេញទី ទាំងគ្រឿងរៀនសូត្រទៀត ក៏មានបរិបូណ៌គ្រប់គ្រាន់ឥតមានខ្វះ អ្នកប្រាជ្ញចេះដឹងក៏មានច្រើន វិជ្ជាអ្វីដែលកើតឡើងក្នុងជាន់នេះ សុទ្ធតែវិសេសសុទ្ធតែប្រាកដទាំងអស់ ព្រោះមានអ្នកប្រាជ្ញក្នុងប្រទេសអឺរ៉ុប ដែលចេះដឹងភាសាបាលីព្រះត្រៃបិដក នូវភាសាសំស្ក្រឹតដ៏ចំណាប់ៗ ក៏ច្រើន ហើយអាចទៅមករកគ្នាបាន នឹងចង់ផ្ទៀងផ្ទាត់គម្ពីរបាលីធមិវិន័យទៅវិញទៅមកបានដោយងាយ លោកអ្នកប្រាជ្ញទាំងនោះមិនមែនចេះដឹងតែដោយសារមើលគម្ពីរបាលីក្បួនខ្នាតនោះទេ គឺចេះដោយមានព្យាយាមបានត្រាច់ចរទៅមើលទីកន្លែង ដែលជាដំណែលធ្លាប់មានព្រះពុទ្ធសាសនាឯណាៗគ្រប់តំបន់ទាំងអស់ តែមានចន្លោះដោយជាក់ច្បាស់នឹងភ្នែក ដូចជាកន្លែងព្រះសម្មាសម្ពុទ្ធទ្រង់ប្រសូតក្ដី ទ្រង់ត្រាស់ដឹងនូវបរមាភិសម្ពោធិញ្ញាណក្ដី ឬទីកន្លែងដែលព្រះពុទ្ធទ្រង់យាងទៅកាន់ទីណាៗក្ដី ក៏បានឃើញទាំងអស់ ហើយបានទាំងថតតួរជាគម្រូដែនទី យកមកឲ្យឃើញដល់ភ្នែកយើងរាល់គ្នាផង នេះជា

ការពិតណាស់ គួរឲ្យសាធុសប្បុរសទាំងឡាយរាល់គ្នា ខំយកចិត្ត ទុកដាក់រៀនសូត្រធម៌វិន័យឲ្យណាស់ តទៅមុខៗថានឹងមានសេចក្តី ចម្រើនវិជ្ជាចំណេះច្រើនក្រៃលែងជាងនេះទៅទៀត ដោយប្រទេស យើងសព្វថ្ងៃនេះ ក៏កាន់តែរុងរឿងស្តុកស្តម្ភមាំមួនជាងពីដើមបន្តិច ហើយ តែថាបើអ្នកប្រតិបត្តិធម៌វិន័យឲ្យភាន់ច្រឡំ ដោយប្រកាន់មាំ ក្នុងអាការទាំង១០យ៉ាង ដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់សម្តែងទុក ក្នុង **កាលាមសូត្រ** ដែលមានក្នុងគម្ពីរអង្គុត្តរនិកាយ តិកនិបាត ប្រារព្ធនឹងពួកជនជាកាលាមគោត្រ នោះហើយព្រះពុទ្ធសាសនា ក៏ នឹងវិនាសសាបសូន្យ អាប់ឱនទៅដោយឆាប់មិនខាន ផ្លូវប្រតិបត្តិ សោតក៏នឹងកើតវិបរិតវិបត្តិប្រែប្រួលរកគោលចារឹកគ្មាន ជាហេតុនាំ ឲ្យមនុស្សល្ងង់វង្វេងវិលវល់អាប់ឥតប្រាជ្ញាយល់ខុសថាជាត្រូវ ហេតុ នេះអ្នកប្រតិបត្តិធម៌វិន័យ ត្រូវឲ្យលះបង់អាការទាំង១០យ៉ាង ដែល ទ្រង់ហាមមិនឲ្យជឿកាន់យកនោះចេញស្រឡះពីខន្ធសន្តាន ទើបនឹង ចម្រើនវិជ្ជាចំណេះនិងផ្លូវប្រតិបត្តិត្រង់ទៅបាន ព្រះពុទ្ធសាសនាក៏ នឹងរុងរឿងដោយសារអ្នកប្រតិបត្តិត្រឹមត្រូវ មិនឲ្យភាន់ច្រឡំនោះឯង ដោយជាក់ស្តែង។

# ឯអាការនាំង១០យ៉ាងនោះ

១-អនុស្សវេន ប្រកាន់ជឿតាមពាក្យដែលឮតាមៗគ្នាមក ជឿដោយឮដំណឹងគេនិយាយតៗគ្នាមក មិនមានពិនិត្យពិចារណា សាកសួរអ្នកប្រាជ្ញ ឬរៀនសូត្រឲ្យឃើញប្រាកដជាក់ច្បាស់តាមពុទ្ធ-វចនៈ ស្រាប់តែឮហើយ ក៏ជឿកាន់យកតែម្តងទៅ។

២-បរម្បរាយ ប្រកាន់ជឿតាមពាក្យបរម្បរា គឺពាក្យជាលំ-ដាប់គ្នាមក ប្រកាន់ជឿទំនៀមទម្លាប់ឯណាខុសៗ ដែលធ្លាប់ឃើញគេធ្វើពីដើមៗមក (ទំនៀមទម្លាប់ខុសចាកព្រះពុទ្ធវចនៈ)។

៣-ឥតិកិរាយ ប្រកាន់ជឿដោយចូលចិត្តថាបានឮមក ថាហេតុនេះយ៉ាងដូច្នេះ ប្រកាន់ជឿដោយអាងថា ខ្ញុំបានឮមកដូច្នេះ ប្រាកដយ៉ាងនេះ (ពាក្យព្រេងដែលគេនិយាយលេងតៗគ្នាមក)។

៤-បិដកសម្បទានេន ប្រកាន់ជឿដោយអាងថា ពាក្យនេះសមមួយអន្លើដោយរបៀបបិដករបស់យើងហើយ គឺអាងក្បួនតម្រាដែលខុសអំពីព្រះពុទ្ធវចនៈ។

៥-តក្កហេតុ ប្រកាន់ជឿដោយសេចក្តីប្រកាន់ នូវហេតុ

ដែលគិតស្មានប្រមាណយកដោយខ្លួនឯង គឺឃើញយ៉ាងណា ក៏ជឿកាន់យកយ៉ាងនោះ (ស្រេចតែនឹងនឹកឃើញ មិនរវល់ពីខុសត្រូវឡើយ)។

**៦-នយហេតុ** ប្រកាន់ជឿដោយគ្នេរគ្នាន់ កាត់តម្រួយផ្សេផ្សំយក គឺសម្គាល់យកពាក្យឯណាមួយ ដែលមានទំនងប្រហែលៗគ្នា មកផ្សេផ្សំផ្គួផ្គងប្រកបគ្នា ហើយក៏ឲ្យឈ្មោះតាមទំនងនោះទៅ ដូចពាក្យថា អានិសង្ស៥ មាតិកា៨ ដែលមានក្នុងកឋិនខន្ធ គឺជាសេចក្តីផ្សេងអំពីសីល៥ សីល៨ ឃើញថា៥ៗ, ៨ៗ ដូចគ្នាដូច្នោះ ក៏ពោលប្រកបឲ្យឈ្មោះថា អានិសង្ស៥នោះ គឺសីល៥ មាតិកា៨ គឺសីល៨ ដូចពាក្យព្រះត្រៃលក្ខណ៍ ឃើញមានអក្សរលាក់ចូលក្នុងនោះខ្លះ ក៏សម្គាល់ថាព្រះត្រៃលក្ខណ៍នោះ អ្នកណានិយាយមិនបានទេ ព្រោះព្រះពុទ្ធ លោកលាក់មិនឲ្យប្រាប់អ្នកណាទេ, ដូចពាក្យថា **នមោ ពុទ្ធាយ** អក្សរ៥តួនេះ ជាពាក្យបាលីសម្រាប់នមស្សការថ្វាយបង្គំព្រះពុទ្ធ ឃើញពាក្យបាលីនេះមានអក្សរ៥តួដូច្នោះ ក៏យកទៅផ្សំប្រកបតម្រូវនឹងព្រះនាមព្រះពុទ្ធទាំង៥ព្រះអង្គ ដែលមានក្នុងភទ្ទកប្បនេះ ហើយពោលថា **នមោ ពុទ្ធាយ** នេះគឺតួព្រះពុទ្ធទាំង៥ព្រះអង្គ

ឯពាក្យប្រកបដូច្នោះ ខុសចាកពុទ្ធវចនៈ។

**៧-អាការបរិវិតក្កេនេន** ប្រកាន់ជឿដោយកិរិយាត្រិះរិះដោយហេតុថា ហេតុនេះល្អ គឺហេតុអ្វីៗដែលកើតឡើងហើយ តែមិនមែនជាធម៌ពិតក៏យកហេតុនោះមកត្រិះរិះផ្ទួគ្គងមើល បើហេតុឯណាដែលពេញចិត្តខ្លួនក៏ពោលថាល្អ ថាត្រូវហើយៗ ក៏ប្រព្រឹត្តកាន់យកតាមសេចក្តីត្រិះរិះនោះទៅ។

**៨-ទិដ្ឋិ និជ្ឈានក្ខន្តិយា** ប្រកាន់ជឿដោយគិតថា ហេតុនេះសមនឹងយោបល់យើង ដែលសម្លឹងឃើញថាគួរអ្នកកាន់យក គឺហេតុអ្វីៗ ដែលមិនមែនជាធម៌ពិត កើតឡើងហើយត្រូវនឹងគំនិតខ្លួនដែលធ្លាប់គិតទុកមក ក៏ចូលចិត្តថាហេតុនោះត្រូវហើយ ពិតហើយៗ ក៏ប្រតិបត្តិកាន់យកតាមហេតុ ដែលសមនឹងយោបល់គំនិតនោះឯងទៅ។

**៩-ភព្វរូបតាយ** ប្រកាន់ជឿដោយគិតថា លោកនេះជាអ្នកអង់អាចចេះដឹងគួរតែយើងជឿកាន់យកតាមពាក្យលោកនេះ គឺបើមានអ្នកណាមួយ គេចេះប្រសប់ឈ្លាសក្នុងពាក្យសម្តីថ្វីមាត់ ចេះនិយាយស្រួលពីរោះឥតអាក់ តែពាក្យសម្តីនោះមិនមែនជាធម៌ពិត

ទេ ស្តាប់ហើយក៏ប្រកាន់ជឿតាមពាក្យដែលគេនិយាយស្រួលនោះទៅ។

១០-សមណោ នោ គរុ ប្រកាន់ជឿដោយគិតថា សមណៈនេះជាគ្រូរបស់យើង គួរយើងកាន់យកតាមពាក្យសមណៈនេះ ប្រ-កាន់ជឿតាមលទ្ធិគ្រូរបស់ខ្លួន បើទុកជាគ្រូនោះនិយាយខុសក៏ដោយក៏ចេះតែជឿកាន់យកតាមទាំងអស់ ទោះមានអ្នកណាមួយក្រៅអំពីគ្រូរបស់ខ្លួន គេនិយាយត្រូវតាមធម៌វិន័យរបស់ព្រះពុទ្ធជាម្ចាស់ដូចម្តេចៗ ក៏មិនជឿ មិនកាន់យកតាម។

អ្នកប្រព្រឹត្តប្រតិបត្តិធម៌វិន័យក្នុងព្រះពុទ្ធសាសនា ត្រូវតែរវាំងតាំងសតិបញ្ញាឲ្យមានមាំមួន កុំឲ្យអាការទាំង១០យ៉ាងនេះ ចូលមកដល់ពាល់ត្រូវក្នុងចិត្តសន្តានបានឡើយ។

មួយទៀតព្រះពុទ្ធសាសនា ដែលនឹងសាបសូន្យថោកថយទៅព្រោះអ្នកប្រតិបត្តិប្រកបដោយហេតុ៥ប្រការ ដែលព្រះសព្វញ្ញូពុទ្ធជាម្ចាស់ទ្រង់សម្តែងទុកក្នុងគម្ពីរអង្គុត្តរនិកាយ បញ្ចកនិបាត។

# ឃ.ហេតុ៥ប្រការនោះគឺ

១-ន សក្កច្ចំ ធម្មំ សុណន្តិ មិនស្តាប់ធម៌ដោយគោរព គឺស្តាប់ធម៌ដោយមិនសង្រួមកាយ វាចា ផ្ចង់ស្មារតីគោរពធម៌ គឺមិនបង្អោនកាយ វាចា ចិត្ត ទៅរកធម៌។

២-ន សក្កច្ចំ ធម្មំ បរិយាបុណន្តិ មិនរៀនទន្ទេញធម៌ដោយគោរព គឺរៀនទន្ទេញតែមាត់ មិនបានប្រុងស្មារតីកំណត់ឲ្យចាំប្រាកដនូវធម៌នោះ។

៣-ន សក្កច្ចំ ធម្មំ ធារេន្តិ មិនបានទ្រទ្រង់នូវធម៌ទុកក្នុងចិត្តដោយគោរព គឺមិនបានរៀននូវធម៌ឲ្យត្រូវតាមអត្ថព្យញ្ជនៈ គឺរៀនធម៌ឲ្យឃ្លាត ឲ្យភ្លាត់ខុសចាកអក្ខរសម្បត្តិ។

៤-ន សក្កច្ចំ ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ មិនពិចារណានូវសេចក្តីនៃធម៌ដែលខ្លួនទ្រទ្រង់ទុកនោះដោយគោរព គឺមិនដឹង មិនយល់ច្បាស់នូវសេចក្តីអធិប្បាយនៃធម៌ដែលខ្លួនទ្រទ្រង់នោះ។

៥-ន សក្កច្ចំ អត្ថមញ្ញាយ បដិបជ្ជន្តិ ដឹងនូវសេចក្តី

អធិប្បាយនៃធម៌ហើយ មិនប្រតិបត្តិតាមដោយគោរព គឺចេះដឹងធម៌-វិន័យ ព្រមទាំងសេចក្តីអធិប្បាយ មិនប្រតិបត្តិឲ្យត្រូវតាមច្បាប់ធម៌-វិន័យនោះ។

អាការទាំង១០យ៉ាងក្តី ហេតុទាំង៥ប្រការក្តី ដូចបានសម្តែងពណ៌នាមកដោយសង្ខេបនេះ ជាហេតុនាំឲ្យព្រះពុទ្ធសាសនាវិនាសសាបសូន្យទៅដោយពិត បើអ្នកប្រតិបត្តិតាំងចិត្ត ប្រុសស្មារតី គិតវៀរលែងអាការ១០យ៉ាង ហេតុ៥ប្រការនេះហើយ ព្រះពុទ្ធសាសនានឹងថ្កុំថ្កើងរុងរឿងវែងឆ្ងាយតទៅ។

(ចប់បរិបូណ៌តែប៉ុណ្ណោះ)

***

Khmer K21
News & Media Website

ស្រាវជ្រាវដោយៈ ជាច់ សុគីម